ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: [illegible] សហវ.[illegible]

# ប្រកាស

## ស្តីពី

## ការបែងចែកភារកិច្ចរបស់អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការចាត់តាំងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៧ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការ នៃក្រសួង និង រដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤.អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៩២៦ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតម្រូវការចាំបាច់ក្នុងការធានាការដឹកនាំឱ្យបានល្អ និងប្រកបដោយប្រសិទ្ធភាពនូវភារកិច្ចដែលរាជរដ្ឋាភិបាលនិងស្ថាប័ននីតិបញ្ញត្តិប្រគល់ជូនឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការឱ្យទទួលខុសត្រូវចំពោះមុខនាយករដ្ឋមន្ត្រី និងរដ្ឋសភាលើវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមការណែនាំរបស់សម្តេចនាយករដ្ឋមន្ត្រី ដែលទទួលផ្ទាល់លើការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ១៨ សសរ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨
- យោងចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៨

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

**សម្រេច**

**ប្រការ១**: កំណត់ភារកិច្ចតាមក្របខ័ណ្ឌការងារជូនអនុរដ្ឋលេខាធិការ ដូចតទៅ :

១. ឯកឧត្តម **ទី តាឃី** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារហិរញ្ញវត្ថុ ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន រួមមាន ក្រសួងទេសចរណ៍ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងគ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី និង ខេត្តរតនគិរី និង បន្តជួយគ្រប់គ្រងកិច្ចការអចលនវត្ថុ (Real Estate) និងជួយកិច្ចការដទៃទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន។

២. ឯកឧត្តម **ស្រ៊ុន តារា** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារហិរញ្ញវត្ថុ ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន រួមមាន ក្រសួងបរិស្ថាន និង ក្រសួងពាណិជ្ជកម្ម និងតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការគ្រប់គ្រងនិងពិភាក្សាលើការងារពាក់ព័ន្ធអង្គការពាណិជ្ជកម្មពិភពលោក (WTO) ព្រមទាំងគ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ និង ក្រុងប៉ៃលិន និងជួយកិច្ចការដទៃទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

៣. ឯកឧត្តម **ញូវណា ឡេង** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារហិរញ្ញវត្ថុ ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន រួមមាន ក្រសួងធនធានទឹក និង ឧតុនិយម និង ក្រសួងធម្មការនិងសាសនា និងគ្រប់គ្រងការងាររបស់គណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ដោយសារគំរោងអភិវឌ្ឍន៍ ព្រមទាំងគ្រប់គ្រងការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខេត្តកំពង់ធំ ខេត្តសៀមរាប និង ខេត្តព្រះវិហារ និងជួយកិច្ចការដទៃទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

៤. ឯកឧត្តម **លី អ៊ាមឡាក់** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារហិរញ្ញវត្ថុ ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន រួមមាន ក្រសួងកិច្ចការនារី និង រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ព្រមទាំងគ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តកណ្តាល ខេត្តស្វាយរៀង និងខេត្តព្រៃវែង និងជួយកិច្ចការដទៃទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

៥. ឯកឧត្តម **សួន ម៉េងគា** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារហិរញ្ញវត្ថុ ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន រួមមាន ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និង ក្រសួងយុត្តិធម៌ និងគ្រប់គ្រងការងារដែលពាក់ព័ន្ធនឹងគំរោងអគ្គិសនី

ព្រមទាំងគ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានីភ្នំពេញ ខេត្តកោះកុង ក្រុងព្រះសីហនុ និងក្រុងកែប និងជួយកិច្ចការដទៃទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

៦. ឯកឧត្តម **ឆាន់ ទឡ្ហៈ** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារហិរញ្ញវត្ថុ ការងារប្រមូលចំណូលនិងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន រួមមាន ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា- ព្រឹទ្ធសភា និងអធិការកិច្ច និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ព្រមទាំងគ្រប់គ្រងការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តកំពង់ស្ពឺ ខេត្តតាកែវ និងខេត្តកំពត និងជួយកិច្ចការដទៃទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

៧. ឯកឧត្តម **ឡើ ហ៊ុនលី** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារហិរញ្ញវត្ថុ ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន រួមមាន ក្រុមប្រឹក្សាធម្មនុញ្ញ និង រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ព្រមទាំងគ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង និងខេត្តពោធិសាត់ និងជួយកិច្ចការដទៃទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន។

**ប្រការ២:** អនុរដ្ឋលេខាធិការ អាចជួយរដ្ឋមន្ត្រី ក្នុងការបំពេញកិច្ចការផ្សេងៗ តាមការប្រគល់សិទ្ធិរបស់រដ្ឋមន្ត្រី ។

**ប្រការ៣:** ភារកិច្ច សិទ្ធិអំណាច នីតិវិធី និងរបៀបរបបបំពេញការងារប្រចាំថ្ងៃ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសលេខ ៩២៦ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៨ ។

**ប្រការ៤:** ប្រកាសលេខ ២១៧ សហវ.ប្រក ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបែងចែកភារកិច្ចរបស់អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៥:** ឯកឧត្តម ដែលមានរាយនាមក្នុងប្រការ១ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបុគ្គលិក គ្រប់ប្រធាននាយកដ្ឋាន និង អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៨

**គាត ឈន់**

__**កន្លែងទទួល**__:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ដូចប្រការ ៥"ដើម្បីអនុវត្ត"
- ឯកសារ- កាលប្បវត្តិ